ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

*******

**កិច្ចព្រមព្រៀង**

**រវាង**

**រោងចក្រ ខេវីធី អ៊ីអឹមប៊ី បេស(ខេមបូឌា) ឯ.ក**

**ជាមួយតំណាងកម្មករនិយោជិតទាំងអស់**

នៅថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០២១វេលាម៉ោង ៨ និង ០០នាទីព្រឹក នៅក្នុងរោងចក្រ ខេវីធី អ៊ីអឹមប៊ីបេស(ខេមបូឌា)ឯ.ក មានកិច្ចប្រជុំមួយរវាងប្រធានរដ្ឋបាល នឹង តំណាងកម្មករ និយោជិត១៥នាក់។ នៅក្នុងអង្គប្រជុំនេះ ប្រធានរដ្ឋបាល បានជូនដំណឹង ដល់កម្មករ និយោជិតទាំងអស់ស្តីពីស្ថានភាពបច្ចុប្បន្ននៃការរីករាលដាលជំងឺកូវីដ១៩ ដែលធ្វើឲ្យរងផលប៉ះពាល់ជាសកល លើគ្រប់វិស័យ ជាពិសេសនៅតាមរោងចក្រ សហគ្រាស បណ្តាលឲ្យមានការកង្វះខាតការផ្គត់ផ្គង់សម្ភារៈផលិតកម្ម ផ្នែកផ្សេងៗក្នុងរោងចក្រ។ហេតុដូចនេះ ក្រុមហ៊ុនសម្រេចចិត្តព្យួរកិច្ចសន្យាការងារ កម្មករ និយោជិតចំនួន ១៥នាក់( ស្រី ៨នាក់) ក្នុងចំណោមកម្មករ និយោជិតសរុបចំនួន ៤១នាក់(ស្រី១៩នាក់) រយៈពេល ២០ថ្ងៃ ដោយគិតចាប់ពីថ្ងៃ ទី១១ ខែ មិថុនា ឆ្នាំ ២០២១ ដល់ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ២០២១។ កម្មករ និយោជិត ទទួលបានអត្ថប្រយោជន៍ និងការទូទាត់ដូចតទៅ ៖

-ប្រាក់ឧបត្ថម្ភពីរោងចក្រ ចំនួន២០ដុល្លារអាមេរិច បើកជូននៅថ្ងៃ ទី១០ ខែ កក្កដា ឆ្នាំ ២០២១ ។

-ប្រាក់ឧបត្ថម្ភពីរាជរដ្ឋាភិបាល ចំនួន ៣០ដុល្លារអាមេរិច តាមរយៈភ្នាក់ងារវីង។

ចំពោះការព្យួរកិច្ចសន្យាការងារនេះយោងតាមសេចក្តីណែនាំ០៤៥/២០ក.ប/ស.ន.ខ.លស្តីពីការព្យួរកិច្ចសន្យាការងារ និងការផ្តាកបង់ភាគទានប.ស.សសម្រាប់រោងចក្រសហគ្រាសគ្រឹះស្ថានក្នុងវិស័យកាត់ដេរនិង ទេសចរណ៍ដែលរងផលប៉ះពាល់ធ្ងន់ធ្ងរដោយសារជំងឺកូវីដ១៩ ។

អង្គប្រជុំបានចប់នៅវេលាម៉ោង ៨និង៥០ នាទី ព្រឹកនាថ្ងៃខែឆ្នាំដដែល ប្រកបដោយបរិយាកាសរីករាយ និងស្និត ស្នាល ក្រោមស្មារតីទទួលខុសត្រូវខ្ពស់ និងយោគយល់សហការគ្នាយ៉ាងរលូន។

រាជធានីភ្នំពេញថ្ងៃទី០៨ ខែ មិថុនា ឆ្នាំ ២០២១

ហត្ថលេខា និង ត្រាក្រុមហ៊ុន

នាយកក្រុមហ៊ុន

KVT EMB BEST (CAMBODIA) CO.,LTD.

KINGDOM OF CAMBODIA

ស្នាមមេដៃតំណាងកម្មករនិយោជិតទាំងអស់

Scanned with CamScanner